ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ១៩៩៤ មស.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបន្ថែមភារកិច្ចដល់ក្រុមការងារពិនិត្យសំណុំឯកសារបេក្ខជនដែលត្រូវបាន ជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការសុខាភិបាលឆ្នាំ២០២១ ដើម្បីបម្រើការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- យោងសេចក្តីសម្រេចលេខ១៩២៧ មស.សសរ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមការងារពិនិត្យសំណុំឯកសារបេក្ខជនដែលត្រូវបានជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការសុខាភិបាលឆ្នាំ២០២១ ដើម្បីបម្រើការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩
- យោងលិខិតលេខ១២១ ស.នប ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល ស្តីពីសំណើសុំជ្រើសរើសបុគ្គលិកចំនួន ១១៤៤នាក់ ដែលកំពុងបម្រើការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ បញ្ចូលក្នុងក្របខណ្ឌសុខាភិបាល និងចាត់ឱ្យទៅបម្រើការងារនៅតាមអង្គភាពនានាក្រោមឱវាទក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ដោយរៀបរៀងតាមប្រភេទក្របខណ្ឌស្របតាមលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌនីមួយៗ
- យោងតាមការចាំបាច់របស់ក្រសួង។

## សម្រេច

**ប្រការ១.-**

ត្រូវបានប្រគល់ភារកិច្ចបន្ថែមដល់ក្រុមការងារដែលបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ លេខ១៩២៧ មស.សសរ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ ឱ្យពិនិត្យសំណុំឯកសារបេក្ខជនចំនួន ១១៤៤នាក់ ថែមទៀតតាមសំណើរបស់ក្រសួងសុខាភិបាលដូចមានយោងខាងលើ ដើម្បីបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការឆ្នាំ២០២១ សម្រាប់បម្រើការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។

**ប្រការ២.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកសាលាភូមិន្ទរដ្ឋបាល គ្រប់អង្គភាពពាក់ព័ន្ធ និងក្រុមការងារពិនិត្យសំណុំឯកសារបេក្ខជនដែលត្រូវបានជ្រើសរើស



ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

បញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការសុខាភិបាលឆ្នាំ២០២១ ដើម្បីបម្រើការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៨កើត ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

ព្រុំ-សុខា

<u>កន្លែងទទួល៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

  "ដើម្បីជូនជ្រាបជាសេចក្តីរាយការណ៍"
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- រដ្ឋបាលរាជធានី ខេត្ត

  "ដើម្បីសហការអនុវត្ត"
- ដូចប្រការ ៥
- ឯកសារ កាលប្បវត្តិ